# ព្រះពុទ្ធបដិមារកឃើញនៅទួលព្រះធាតុ ខេត្តកំពង់ស្ពឺ

ព្រះពុទ្ធសាសនា ក៏មិនខុសគ្នាប៉ុន្មានពីព្រហ្មញ្ញសាសនាដែរ គឺបានសាយភាយឥទ្ធិពលពីស្រុកឥណ្ឌាហូរចូលមកស្រុកខ្មែរនៅសម័យដំបូងៗ (ហ្វូណាន និងចេនឡា) តាមរយៈទំនាក់ទំនងផ្លូវសមុទ្រ។ គេសង្កេតឃើញថា បុរាណវត្ថុដំបូងៗដែលទាក់ទងនឹងព្រះពុទ្ធសាសនាច្រើនតែរកឃើញនៅតំបន់ភាគខាងត្បូងប្រទេស ដូចជា ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ។ល។ ក្នុងនោះ មានព្រះពុទ្ធបដិមាមួយអង្គគេបានរកឃើញនៅទួលព្រះធាតុ ស្ថិតនៅឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ តើព្រះពុទ្ធបដិមានេះមានប្រវត្តិ និងលក្ខណៈបែបណាខ្លះ?

ព្រះពុទ្ធបដិមានេះ មានកម្ពស់ ៩៤ស.ម. ទទឹង ៣៣ស.ម. រកឃើញនៅទួលប្រាសាទឥដ្ឋមួយដែលមានឈ្មោះថា "ទួលព្រះធាតុ" ត្រង់ផ្នែកខាងត្បូងទួល នៅក្នុងឆ្នាំ១៩៣៥។ ក្រោយមកសាលាបារាំងចុងបូព៌ាប្រទេស បានបញ្ជូនព្រះពុទ្ធបដិមាអង្គនេះមករក្សាទុកនិងដាក់តាំងបង្ហាញនៅសារមន្ទីរហ្គីមេត នាទីក្រុងប៉ារីស ប្រទេសបារាំង ដោយមានលេខបញ្ជី MG18891។ នៅពេលប្រទះឃើញបដិមានេះដំបូង ព្រះសិរព្រះពុទ្ធអង្គបានដាច់ចេញពីព្រះកាយ ហើយព្រះហស្តឆ្វេងដាច់ត្រឹមកដៃ និងព្រះហស្តស្តាំបាក់បែកម្រាមតិចតួច (រូបលេខ១-២)។ ព្រះពុទ្ធអង្គទ្រង់ឈរនៅលើថ្មទម្រមានរាងប្រាំបីជ្រុងតូចមួយ ក្នុងទម្រង់ព្រះភក្ត្របែបស្ងឹងស្ងាធដោយការបិទព្រះនេត្រទាំងសងខាង ព្រះកេសាមានរាងដូចគូទខ្យង បបូរមាត់ក្រាស់ ច្រមុះមានខ្នង់ ស្ទឹកត្រចៀកវែង និងគ្រងដោយស្បង់វែងធ្លាក់ដល់កជើង (រូបលេខ៣-៧)។ បើទោះបីព្រះហស្តខាងឆ្វេងបាក់បែកក៏ដោយ ក៏ព្រះហស្តខាងស្តាំបង្ហាញថា ព្រះពុទ្ធរូបអង្គនេះធ្លាក់ក្នុងកាយវិការវិតក៌មុទ្រដែរ។ វិតក៌មុទ្រសំដៅដល់កាយវិការដៃស្តាំមានម្រាមចង្អុលនិងម្រាមមេផ្ទួបគ្នា ហើយម្រាមបីទៀតលើកទៅលើ និងដៃឆ្វេងម្រាមចង្អុលនិងម្រាមមេផ្ទួបគ្នាដូចគ្នា តែម្រាមបីទៀតទម្លាក់ចុះក្រោម។ វិតក៌មុទ្រសំដៅលើកាយវិការនៃការបង្រៀន ឬសំដែងធម៌របស់ព្រះពុទ្ធអង្គដល់សត្វលោក។ ព្រះពុទ្ធរូបដែលមានកាយវិការរបៀបនេះ គេធ្លាប់រកឃើញនៅទួលអង្គរិល ខេត្តកំពង់ស្ពឺ។ វាប្រាកដណាស់ថាកាយវិការនេះមានប្រភពមកពីស្រុកឥណ្ឌា ជាពិសេសសិល្បៈសម័យគុប្ត (សិល្បៈសាន៉ាថ និងអាជណ្តា) ប៉ុន្តែនៅក្នុងសិល្បៈខ្មែរដំបូងៗហាក់មិនសូវនិយមខ្លាំងប៉ុន្មានឡើយ ផ្ទុយពីសិល្បៈទ្វារវតី (មន) ដែលស្ទើរគ្រប់ព្រះពុទ្ធរូបសុទ្ធសឹងមានកាយវិការនេះ។ ហេតុដូច្នេះហើយ ទើបនាំឱ្យលោក Pierre Dupont យល់ថា ព្រះពុទ្ធរូបដែលរកឃើញនៅទួលព្រះធាតុ ខេត្តកំពង់ស្ពឺនេះ អាចមានទទួលឥទ្ធិពលសិល្បៈទ្វារវតី។ ទោះជាយ៉ាងណាក៏ដោយ ការស្នើរបស់លោកនៅមានការចំណុច

ដែលពិបាកទទួលយកច្រើន ដ្បិតវាអាចទៅរួចដែរថា ព្រះពុទ្ធរូបនេះ និងព្រះពុទ្ធរូបសិល្បៈទ្វារវតី ជាច្រើននោះ សុទ្ធសឹងទទួលឥទ្ធិពលសិល្បៈពីឥណ្ឌាដូចគ្នា។

អ្វីដែលគួរឱ្យចាប់អារម្មណ៍បន្ថែមនោះគឺ នៅលើខ្នងព្រះពុទ្ធរូបអង្គនេះមានសិលាចារឹក ចំនួន ២ បន្ទាត់ សរសេរជាភាសាបាលី ហើយសិលាចារឹកនេះចុះបញ្ជីលេខ K.820 ដែលមាន ប្រភេទអក្សរដំបូងៗ (ស.វ.ទី៧ - ៨) (រូបលេខ២៨)។ សិលាចារឹកចំនួនពីរបន្ទាត់នេះ មានខ្លឹមសារដូច សិលាចារឹកជាច្រើនទៀតដូចជា សិលាចារឹកអង្គរបុរី (Ka. 86) សិលាចារឹកវត្តស្រះឈូក Ka.110 និងសិលាចារឹកមួយចំនួនទៀតរកឃើញនៅស្រុកសៀម។ អ្នកស្រាវជ្រាវជាច្រើនតែងយល់ថា ដោយសារតែសិលាចារឹកនេះសរសេរជាភាសាបាលី វាបានក្លាយជាសក្ខីកម្មមួយបញ្ជាក់អំពីព្រះ ពុទ្ធនិកាយថេរវាទ (ស្ថិរវាទ)។ ខ្លឹមសារទាំងស្រុងនៃសិលាចារឹកដែលចារនៅលើខ្នងព្រះពុទ្ធរូបមាន ដូចតទៅ៖

**១. យេ ធម្មា ហេតុប្រភវា តេសម ហេតុំ តថាគតោ អវច**

**២. តេសញ្ច យោ និរោធោ ឯវំវាទី មហាសមនោ**

ប្រែថា៖ "ធម៌ទាំងឡាយកើតឡើងអំពីហេតុ ព្រះតថាគតព្រះអង្គទ្រង់ត្រាស់ និងរំលត់នូវ ហេតុនៃធម៌ទាំងឡាយនោះ តាមឱវាទរបស់ព្រះមហាសមណដែលទ្រង់តែងតែបានអប់រំ។

សរុបជារួមមក តាមប្រភពសិលាចារឹក (រូបរាងអក្សរ) និងផ្នែកសិល្បៈនៃព្រះពុទ្ធរូបដែល រកឃើញនៅទួលព្រះធាតុ ខេត្តកំពង់ស្ពឺ នាំឱ្យអ្នកស្រាវជ្រាវជាទូទៅសន្និដ្ឋានថា បដិមានេះសាង ឡើងនៅរវាងស.វ.ទី៧ ឬទី៨។ ព្រះពុទ្ធព្រះភគវន្តសក្យមុនីសម្ពុទ្ធមួយអង្គនេះ គឺជាបុរាណវត្ថុដ៏ សំខាន់ដើម្បីឱ្យដឹងអំពីការគោរពប្រណិប័តន៍ព្រះពុទ្ធសាសនានៅសម័យបុរាណ ជាពិសេស តាម រយៈសិលាចារឹកសរសេរជាភាសាបាលីទៀតផងនោះ ព្រះពុទ្ធរូបនេះ ក៏អាចជាផ្នែកមួយនៃ និកាយថេរវាទនៅសម័យបុរាណផងដែរ។

## ឯកសារយោង

Baptiste, P. & Zéphir, T. 2008. *L'Art Khmer dans les collections du musée Guimet,* Paris.

Boisselier, J. 1966, "*Asie du Sud-Est, Le Cambodge* ", Tome I, Paris.

Dalet, R. 1936. 'Recherches archéologiques au Cambodge', *BEFEO,* Tome, XXXVI, Hanoi.

Coedès, G. 1964. *Inscription du Cambodge,* Tome, VII, Hanoi.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

Dupont, P. 1955, *La Statuaire préangkorienne, Artibus Asiae,* Supple mentum XV, Artibus Asiae Publishers, Ascona.

Skilling, P. 2002. ‘Some citation Inscription from South-East Asia’, *The Journal of the Pali Text Society,* vol. XXVII, 2002, p.159-175.



*រូបលេខ១.២៖ ព្រះពុទ្ធរូបរកឃើញនៅទួលព្រះធាតុ ខេត្តកំពង់ស្ពឺ នៅទីតាំងដើម ថតឆ្នាំ១៩៣៥*

*(ប្រភព៖ សាលាបារាំងចុងបូព៌ាប្រទេស)*

អត្ថបទដោយ៖ ម៉ង់ វ៉ាលី




រូបលេខ៣៖ ព្រះពុទ្ធរូបរកឃើញនៅទួលព្រះធាតុ ខេត្តកំពង់ស្ពឺ តាំងនៅសារមន្ទីរជាតិហ្គីមេត ប្រទេសបារាំង
(មើលពីមុខចំ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៤៖ ព្រះពុទ្ធរូបរកឃើញនៅទួលព្រះធាតុ ខេត្តកំពង់ស្ពឺ តាំងនៅសារមន្ទីរជាតិហ្គីមេត ប្រទេសបារាំង (មើលពីចំហៀងខាងឆ្វេង)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៥៖ ព្រះពុទ្ធរូបរកឃើញនៅទួលព្រះធាតុ ខេត្តកំពង់ស្ពឺ តាំងនៅសារមន្ទីរជាតិហ្គីមេត ប្រទេសបារាំង (មើលពីចំហៀងខាងស្តាំ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



*រូបលេខ៦៖ ព្រះពុទ្ធរូបរកឃើញនៅទួលព្រះធាតុ ខេត្តកំពង់ស្ពឺ តាំងនៅសារមន្ទីរជាតិហ្គីមេត ប្រទេសបារាំង (មើលពីលម្អិតកំណាត់ខ្លួនឡើងលើ)*

*អត្ថបទដោយ៖ ម៉ង់ រ៉ាលី*



រូបលេខ៧៖ ព្រះពុទ្ធរូបរកឃើញនៅទួលព្រះធាតុ ខេត្តកំពង់ស្ពឺ តាំងនៅសារមន្ទីរជាតិហ្គីមេត ប្រទេសបារាំង
(មើលពីមុខខាងក្រោយចំ)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ៨៖ សិលាចារឹកភាសាបាលីនៅលើខ្នងព្រះពុទ្ធរូបមកពីទួលព្រះធាតុ ខេត្តកំពង់ស្ពឺK.820

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី